**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៩ សសរ

## សេចក្តីសម្រេច
## ស្តីអំពីរបៀបរបបការងារ និងការបែងចែកភារកិច្ច
## របស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/001 ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញ បន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១:** កំណត់របៀបរបបការងារ និងបែងចែកភារកិច្ចជូននាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី ដែលទទួលបន្ទុកបេសកកម្មពិសេស សំដៅធានាការអនុវត្តច្បាប់ និងដឹកនាំកិច្ចការទូទៅរបស់រដ្ឋ ។

**ប្រការ ២:** ចំពោះនាយករដ្ឋមន្ត្រី: **សម្តេច ហ៊ុន សែន:** នាយករដ្ឋមន្ត្រីទទួលបន្ទុកដឹកនាំរួម ការងាររបស់គណៈរដ្ឋមន្ត្រី ចាត់ចែងបញ្ហារាស់សកម្មភាពរបស់រាជរដ្ឋាភិបាលលើគ្រប់វិស័យ និងទទួលផ្ទាល់លើការងារគ្រប់គ្រងគ្រោះមហន្តរាយ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**ប្រការ ៣:** ចំពោះឧបនាយករដ្ឋមន្ត្រី :

១-**ឯកឧត្តម ស ខេង** : ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រចាំការដោះស្រាយការងារប្រចាំថ្ងៃ ជានាយករដ្ឋមន្ត្រីស្តីទី ពេលអវត្តមាននាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រីលើកិច្ចការសន្តិសុខជាតិ ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ជួញដូរមនុស្ស ដឹកនាំប្រតិបត្តិការទប់ស្កាត់ និងប្រឆាំងភេរវកម្ម ដឹកនាំកិច្ចការវិមជ្ឈការ និងសហវិមជ្ឈការ គាំទ្រ កម្មវិធីសីលា ការកែទំរង់ការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ ។ ជាមួយនេះ ជួយនាយករដ្ឋមន្ត្រីក្នុងការងារសម្របសម្រួលគ្រប់គ្រងក្រសួង

ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ក្រសួងផែនការ ក្រសួងបរិស្ថាន និងក្រសួងយុត្តិធម៌ ។

២_**ឯកឧត្តម សុខ អាន** : ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកសម្របសម្រួលកិច្ចការ សំរាប់គណៈរដ្ឋមន្ត្រី នាយករដ្ឋមន្ត្រី និងបណ្តាឧបនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រីក្នុងការងារតាមដានសម្របសម្រួល និងដឹកនាំកិច្ចការកែទំរង់រដ្ឋ ដំណើរការតុលាការ កាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ការងារបំផ្លាញមីន និងជួយជនពិការដោយសារមីន និងពត៌មានវិទ្យា។ ជួយនាយករដ្ឋមន្ត្រីក្នុងការរៀបចំចម្លើយតបនឹងសំនួររបស់សមាជិករដ្ឋសភា តាមនីតិវិធីដូចមានចែងក្នុងមាត្រាទី ៩៦ នៃរដ្ឋធម្មនុញ្ញ។ ជាមួយនេះ ជួយនាយករដ្ឋមន្ត្រី ក្នុងការងារសម្របសម្រួលគ្រប់គ្រងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងពត៌មាន ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងដឹកនាំអាជ្ញាធរជាតិប្រែងកាត និងដោះស្រាយជម្លោះដីធ្លី ។

៣_**ឯកឧត្តម លី ធុាយស្រេង** : ឧបនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រីក្នុងការងារសម្របសម្រួលគ្រប់គ្រងក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកិច្ចការនារី និងក្រសួងធម្មការ និងកិច្ចការសាសនា ។

៤_**ឯកឧត្តម ទៀ បាញ់** : ឧបនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រីលើការងារការពារជាតិ ទទួលសិទ្ធិពីនាយករដ្ឋមន្ត្រីក្នុងការងារគ្រប់គ្រង និងបញ្ជាកងរាជអាវុធហត្ថលើផ្ទៃប្រទេស។ ជាមួយនេះ ជួយនាយករដ្ឋមន្ត្រីក្នុងការងារសម្របសម្រួលគ្រប់គ្រងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹកនិងឧតុនិយម និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

៥_**ឯកឧត្តម ហោ ណាំហុង** : ឧបនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រីលើការងារ ការបរទេស និងសហប្រតិបត្តិការអន្តរជាតិទូទៅ។ ជាមួយនេះ ជួយនាយករដ្ឋមន្ត្រីក្នុងការងារសម្របសម្រួល គ្រប់គ្រងក្រសួងពាណិជ្ជកម្ម និងគណៈកម្មាធិការជាតិទន្លេមេគង្គ ។

៦_**ឯកឧត្តម ញឹក ប៊ុនឆៃ**: ឧបនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រីក្នុងការងារសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម និងជួយឯកឧត្តម ទៀ បាញ់ ក្នុងការងារគ្រប់គ្រងនិងបញ្ជាកងរាជអាវុធ_ហត្ថ លើផ្ទៃប្រទេស ។ ទន្ទឹមនេះឯកឧត្តមឧបនាយករដ្ឋមន្ត្រី ញឹក ប៊ុនឆៃ ជួយនាយករដ្ឋមន្ត្រីលើការងារសម្របសម្រួលគ្រប់គ្រងក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងសុខាភិបាល ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងទេសចរណ៍ ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ញឹក ប៊ុនឆៃ ដឹកនាំគណៈកម្មាធិការជាតិដើម្បីប្រជាជននិងការអភិវឌ្ឍន៍ គណៈកម្មការត្រួតពិនិត្យដោះស្រាយបាតុភាព និងអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែនកម្ពុជាជាមួយប្រទេសជិតខាង ចំណុះអោយអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន និងកិច្ចការមួយចំនួនទៀតតាមការប្រគល់ភារកិច្ចពីនាយករដ្ឋមន្ត្រី ។

**ប្រការ ៤**:នាយករដ្ឋមន្ត្រី និងឧបនាយករដ្ឋមន្ត្រី ជាគណៈអចិន្ត្រៃយ៍នៃគណៈរដ្ឋមន្ត្រី ដែលត្រូវប្រជុំពិគ្រោះការងារតាមការកោះអញ្ជើញពីនាយករដ្ឋមន្ត្រី ឬពីនាយករដ្ឋមន្ត្រីស្តីទី ។

**ប្រការ ៥:** ឧបនាយករដ្ឋមន្ត្រីទទួលអនុវត្តការងារ ឬបេសកកម្មផ្សេងទៀតដែលនាយករដ្ឋមន្ត្រីប្រគល់ជូន ស្រប តាមមាត្រា ១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

**ប្រការ ៦:** ឧបនាយករដ្ឋមន្ត្រី ១ រូប១ មានទីប្រឹក្សា ៤ រូប ក្នុងនោះ ២ រូប មានឋានៈស្មើរដ្ឋលេខាធិការ ២ រូប មានឋានៈស្មើអនុរដ្ឋលេខាធិការ និងជំនួយការ ៣ រូប ក្នុងនោះ ១ រូប មានឋានៈស្មើ អគ្គនាយក ១ រូប មានឋានៈស្មើអគ្គនាយករង និង ១ រូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**ប្រការ ៧:** ចំពោះទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស :

១_ឯកឧត្តម ហុង ស៊ុនហួត ទេសរដ្ឋមន្ត្រីទទួលបន្ទុកដឹកនាំអាជ្ញាធរអេដស៍

២_ឯកឧត្តម ឃី តាំងលឹម ទេសរដ្ឋមន្ត្រីទទួលបន្ទុកជារដ្ឋមន្ត្រីអមមហាអនុតំបន់ទន្លេមេគង្គ

៣_ឯកឧត្តម វេង សិរីវុឌ្ឍ ទេសរដ្ឋមន្ត្រីទទួលបន្ទុកដឹកនាំអាជ្ញាធរជាតិទេសចរណ៍កម្ពុជា និងជាប្រធាន ក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ

៤_ឯកឧត្តម ញឹម វណ្ណដា ទេសរដ្ឋមន្ត្រីទទួលបន្ទុកជាអនុប្រធានទី ១ នៃគណៈកម្មាធិការជាតិគ្រប់គ្រង គ្រោះមហន្តរាយ

៥_ឯកឧត្តម តាវ សេងហួរ ទេសរដ្ឋមន្ត្រីទទួលបន្ទុកជាអនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

៦_ឯកឧត្តម ស៊ី កុសល ទេសរដ្ឋមន្ត្រីទទួលបន្ទុកជាអនុប្រធានទី ២ នៃគណៈកម្មាធិការជាតិគ្រប់គ្រង គ្រោះមហន្តរាយ

**ប្រការ ៨:** ទេសរដ្ឋមន្ត្រីទទួលអនុវត្តបន្ថែមនូវការងារផ្សេងទៀតដែលនាយករដ្ឋមន្ត្រីប្រគល់ជូន ។

**ប្រការ ៩:** ទេសរដ្ឋមន្ត្រីដែលទទួលបន្ទុកបេសកកម្មពិសេសមានជំនួយការ ២ រូប ក្នុងនោះ ១ រូប មានឋានៈ ស្មើអគ្គនាយករង និង ១ រូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**ប្រការ១០:** នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង_ស្ថាប័ន ត្រូវ អនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិនា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

_ក្រសួងព្រះបរមរាជវាំង
_អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
_អគ្គលេខាធិការដ្ឋានរដ្ឋសភា
_ទីស្តីការគណៈរដ្ឋមន្ត្រី
_អគ្គលេខាធិការរាជរដ្ឋាភិបាល
_ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
_ដូចប្រការ ២_៣_៧_១០
_ឯកសារ_កាលប្បវត្តិ